ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៨ អនក្រ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការរៀបចំសន្និសីទថ្នាក់រដ្ឋមន្ត្រី នៃបណ្តាប្រទេសអភិវឌ្ឍន៍តិចតួច

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មការរៀបចំសន្និសីទថ្នាក់រដ្ឋមន្ត្រី នៃបណ្តាប្រទេសអភិវឌ្ឍន៍តិចតួច ដែលនឹងប្រព្រឹត្តិធ្វើចាប់ពីថ្ងៃទី១៩-២១ ខែវិច្ឆិកា ឆ្នាំ២០០៨ នៅខេត្តសៀមរាប ដែលមានសមាសភាពដូចរាយនាមខាងក្រោម :

| | | |
|---|---|---|
| ១. ឯកឧត្តម ចម ប្រសិទ្ធ | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | ប្រធាន |
| ២. ឯកឧត្តម ស៊ុយ សែម | រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | អនុប្រធាន |

| | | |
|---|---|---|
| ៣. ឯកឧត្តម អ៊ុក រ៉ាប៊ុន | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤. ឯកឧត្តម តោគ សុទណ្ណរិទ្ធ | រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៥. ឯកឧត្តម អ៊ុច បូររិទ្ធ | រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៦. ឯកឧត្តម ផាន សួរស័ក្តិ | រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៧. ឯ.ឧ ឧត្តមសេនីយ៍ឯក យូ ស៊ីនឡុង | អគ្គស្នងការរងនគរបាលជាតិ ក្រសួងមហាផ្ទៃ | សមាជិក |
| ៨. ឯ.ឧ ឧត្តមសេនីយ៍ឯក សៅ សុខា | មេបញ្ជាការកងរាជអាវុធហត្ថ ក្រសួងការពារជាតិ | សមាជិក |
| ៩. ឯកឧត្តម ស៊ូ ភិរិន្ទ | អភិបាលខេត្តសៀមរាប | សមាជិក |
| ១០. ឯកឧត្តម សុខ សុភក្រ្ត | អគ្គនាយកពាណិជ្ជកម្មអន្តរជាតិ ក្រសួងពាណិជ្ជកម្ម | សមាជិក |

**ប្រការ ២.-**

គណៈកម្មការរៀបចំសន្និសីទថ្នាក់រដ្ឋមន្ត្រី នៃបណ្តាប្រទេសអភិវឌ្ឍន៍តិចតួច មានភារកិច្ចដូចតទៅ :

- រៀបចំកម្មវិធីសន្និសីទ និងពិធីការឱ្យបានសមស្រប
- រៀបចំគំរោងចំណាយសម្រាប់រៀបចំសន្និសីទខាងលើ ឱ្យស្របតាមគោលការណ៍ហិរញ្ញវត្ថុ
- សម្របសម្រួល រៀបចំការពារសន្តិសុខជូនគណៈប្រតិភូ និងសមាជិកចូលរួមសន្និសីទ ក្នុងឱកាសស្នាក់នៅ និងទស្សនកិច្ចនៅតាមកន្លែងនានា ឱ្យបានល្អ
- ចាត់ចែងការសំដែងសិល្បៈប្រពៃណី ជូនគណៈប្រតិភូក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ
- សម្របសម្រួល និងរៀបចំដំណើរទស្សនាចរជូនគណៈប្រតិភូតាមកម្មវិធីដែលបានគ្រោងទុក
- សម្របសម្រួលជាមួយប្រព័ន្ធឃោសនាជាតិ និងអន្តរជាតិ ដើម្បីផ្សព្វផ្សាយពីការរៀបចំសន្និសីទ ។

**ប្រការ ៣.-**

ប្រធានគណៈកម្មការរៀបចំសន្និសីទ មានសិទ្ធិអញ្ជើញមន្ត្រីជំនាញនៃក្រសួង ស្ថាប័ន រាជធានី ខេត្តពាក់ព័ន្ធនានា ឱ្យមកចូលរួមប្រជុំ ដើម្បីពិភាក្សា និងដោះស្រាយការងារដែលចាំបាច់ ។

**ប្រការ ៤.-**

ប្រធានគណៈកម្មការរៀបចំសន្និសីទ អាចបង្កើតអនុគណៈកម្មការជំនាញផ្សេងទៀត តាមការចាំបាច់ ។

**ប្រការ ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អភិបាលខេត្តសៀមរាប រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ វិច្ឆិកា ឆ្នាំ ២០០៨

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- ឯកសារ-កាលប្បវត្តិ